**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

ទទួល ថ្ងៃទី 15 ខែ 12 ឆ្នាំ 11

ម៉ោង 11H00'

លេខ............................ឯកសារ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** 1706 **ក.ប** / ស.ជ.ណ

# សេចក្តីជូនដំណឹង

គោរពតាមអនុសាសន៍ជាគោលការណ៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅក្នុងវេទិកាសម្រាប់វិស័យឯកជន និងរាជរដ្ឋាភិបាលលើកទី ១៦ កាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០១១ និងលិខិតលេខ ១៤៧៧ សជណ. អវ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងចំពោះអង្គការសហជីពគ្រប់ថ្នាក់ សមាគមនិយោជក កម្មករនិយោជិត និងនិយោជក នៃរោងចក្រ សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា សូមអនុវត្តរបៀបផ្តល់ប្រាក់ឧបត្ថម្ភថៃទាំសុខភាព ដូចខាងក្រោម ៖

១- ផ្តល់ប្រាក់ឧបត្ថម្ភថៃទាំសុខភាពចំនួន ៥(ប្រាំ)ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយខែ សម្រាប់កម្មករនិយោជិតទាំងអស់ ដែលធ្វើការផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើង។ ប្រាក់ឧបត្ថម្ភនេះ មិនត្រូវបានបូកបញ្ចូលធ្វើជាប្រាក់ឈ្នួលសុទ្ធសាធទេ (ប្រាក់ឈ្នួលគោល)។

២- ចំពោះកម្មករនិយោជិតដែលចូលធ្វើការថ្មីក្នុងខែដំបូង មានរយៈពេលមិនគ្រប់ ២៦(ម្ភៃប្រាំមួយ)ថ្ងៃ នៃថ្ងៃធ្វើការងារក្នុងមួយខែ គិតត្រឹមថ្ងៃបើកប្រាក់ឈ្នួល ត្រូវទទួលបានប្រាក់ឧបត្ថម្ភថៃទាំសុខភាព ដូចខាងក្រោម ៖

ក- កម្មករនិយោជិតធ្វើការបានរយៈពេល ១៣(ដប់បី) ថ្ងៃចុះក្រោមទទួលបានប្រាក់ឧបត្ថម្ភថៃទាំសុខភាពចំនួនពាក់កណ្តាល គឺ ២,៥ ដុល្លារសហរដ្ឋអាមេរិក។

ខ- កម្មករនិយោជិតធ្វើការបានរយៈពេល ១៤(ដប់បួន)ថ្ងៃឡើងទៅ ទទួលបានប្រាក់ឧបត្ថម្ភថៃទាំសុខភាពពេញ គឺចំនួន ៥ ដុល្លារសហរដ្ឋអាមេរិក។

៣- ចំពោះកម្មករនិយោជិតដែលធ្វើការយកកម្រៃតាមថ្ងៃ ឬតាមសប្តាហ៍ ប្រាក់ឧបត្ថម្ភថែទាំសុខភាពនេះ ត្រូវបានគណនាតាមអត្រាប្រចាំថ្ងៃ គឺទទួលបាន ០,២(សូន្យក្បៀសពីរ) ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយថ្ងៃ។

៤- ប្រាក់ឧបត្ថម្ភថែទាំសុខភាពនេះ អនុវត្តចាប់ពីថ្ងៃទី០១ខែមករា ឆ្នាំ២០១២ តទៅ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អង្គការសហជីពគ្រប់លំដាប់ថ្នាក់ សមាគមនិយោជក កម្មករនិយោជិត និងនិយោជក នៃរោងចក្រ សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងទាំងអស់ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរ និងធានាបាននូវប្រសិទ្ធិភាពខ្ពស់។

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

**<u>ចម្លងជូន:</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  " ដើម្បីជូនជ្រាប "
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
- គ្រប់សមាគមនិយោជក
- គ្រប់សហព័ន្ធសហជីព
  " ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- កាលប្បវត្តិ - ឯកសារ